# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០១៧ សហវ.

រាជធានីភ្នំពេញ,ថ្ងៃទី០៧ខែ ... ឆ្នាំ២០០៦

# សារាចរណែនាំ
## ស្តីពីការរៀបចំផែនការលទ្ធកម្ម
### ៣៣១០៧៣

យោងអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ សារាចរណែនាំ ស្តីពីការរៀបចំផែនការលទ្ធកម្មត្រូវបានបង្កើតឡើង ក្នុងគោលបំណងសំរេចអោយបាននូវផែនការលទ្ធកម្មមួយ ដែលមានលក្ខណៈច្បាស់លាស់ គ្រប់ជ្រុងជ្រោយ ប្រកបដោយភាពម្ចាស់ការ និងការទទួលខុសត្រូវខ្ពស់ ។

ការរៀបចំផែនការលទ្ធកម្ម គឺជាការកសាងកម្មវិធីការងារសំរាប់អនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ។

ឆ្នាំ២០០៧ ជាឆ្នាំដំបូងដែលរាជរដ្ឋាភិបាល បង្កើតអោយមានផែនការលទ្ធកម្មក្នុងកំណែទំរង់ ប្រព័ន្ធលទ្ធកម្មសាធារណៈ ដើម្បីលើកកំពស់ពង្រឹងយន្តការគ្រប់គ្រងចំណាយថវិការដ្ឋ អោយមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់ រួមចំណែកក្នុងការសន្សំសំចៃថវិការដ្ឋអោយបានកាន់តែប្រសើរឡើង ក្នុងគោលដៅបង្កើន ការជឿទុកចិត្តបានលើការគ្រប់គ្រងថវិកា ។

ដើម្បីឆ្លើយតបតាមគោលបំណងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីការរៀបចំផែនការលទ្ធកម្មដូចខាងក្រោម :

## I.អត្ថប្រយោជន៍ នៃផែនការលទ្ធកម្ម

ផែនការលទ្ធកម្មផ្តល់នូវអត្ថប្រយោជន៍សំខាន់ៗ ដូចខាងក្រោម :

-ជំរុញការគ្រប់គ្រង ការតាមដាន និងលើកកំពស់ការអនុវត្តន៍កិច្ចលទ្ធកម្មអោយកាន់តែមានប្រសិទ្ធភាពខ្ពស់ ។

-បង្ហាញអោយដឹងអំពីតំរូវការទំនិញ សំណង់ សេវា ទាំងបរិមាណ និងតំលៃសរុបប្រចាំឆ្នាំ របស់ស្ថាប័ននីមួយៗ ។

-ដឹងនូវចំនួនកិច្ចលទ្ធកម្ម តំលៃគំរោងនីមួយៗ តាមវិធីសាស្ត្រ តាមមុខសញ្ញា និងតាមប្រភេទលទ្ធកម្ម ។

-បញ្ជាក់ច្បាស់អំពីកិច្ចលទ្ធកម្មនីមួយៗ ដែលត្រូវដំណើរការតាមលំដាប់លំដោយ ចាប់ពីកាលបរិច្ឆេទចាប់ផ្តើម



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone 855-23-724 664 Fax 855-23-427 798

រហូតដល់ការប្រគល់-ទទួល ព្រមទាំងកាលបរិច្ឆេទ និងសមាមាត្រដែលត្រូវទូទាត់ ។

-សំរាប់ធ្វើជាមូលដ្ឋាន ក្នុងការរៀបចំកម្មវិធីចំណាយប្រចាំត្រីមាស របស់ស្ថាប័នអនុវត្តលទ្ធកម្ម ។

-សំរាប់តាមដានការអនុវត្តន៍កិច្ចលទ្ធកម្ម ដើម្បីឆ្លុះបញ្ចាំងអំពីចំណុចខ្លាំង ចំណុចខ្សោយ ឬ ការយឺតយ៉ាវក្នុងដំណើរការលទ្ធកម្ម ដែលជាបុព្វបទ នាំអោយអ្នកគ្រប់គ្រងអាចចាត់វិធានការកែលំអ ដោយលុបបំបាត់ ឬ ពង្រឹងបន្ថែម ដើម្បីធានាថា កិច្ចលទ្ធកម្មចាប់ផ្តើមបានទាន់ពេលវេលា ជៀសវាងបាននូវការយឺតយ៉ាវ ហើយជំរុញអោយមានការប្រកួតប្រជែងពេញលេញ ទទួលបាននូវ គណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាពខ្ពស់ ។

-សំរាប់ប្រើជារបាយការណ៍ព័ត៌មានដល់អ្នកប្រើប្រាស់ចុងក្រោយ ។

## II.ភារកិច្ច របស់ស្ថាប័នអនុវត្តលទ្ធកម្ម

-ស្ថាប័នអនុវត្តលទ្ធកម្ម ចាំបាច់ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ របស់ខ្លួនតាមគំរូដែលបានផ្តល់ដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-ប្រធានស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវពិនិត្យ និងអនុម័តលើផែនការលទ្ធកម្ម រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈនាយកដ្ឋានលទ្ធកម្ម សាធារណៈនៅសប្តាហ៍ទី១ ខែមករា នៃឆ្នាំសារពើពន្ធ ។

-រាល់គំរោងចំណាយ ដែលត្រូវអនុវត្តតាមវិធីសាស្ត្រលទ្ធកម្ម ត្រូវកត់ត្រាទាំងអស់តាមលំដាប់លំដោយ បញ្ចូលក្នុងផែនការលទ្ធកម្ម។ ករណីមិនមានកត់ត្រា ក្នុងផែនការលទ្ធកម្ម មិនត្រូវបានអនុញ្ញាតអោយធ្វើកិច្ចលទ្ធកម្មឡើយ ហើយសាមីក្រសួង ស្ថាប័នត្រូវទទួលខុសត្រូវ លើ រាល់បាតុភាពអសកម្ម ដែលនឹងកើតឡើង ជាយថាហេតុ។

-ស្ថាប័នអនុវត្តលទ្ធកម្មត្រូវចាត់ចែងអនុវត្តកិច្ចលទ្ធកម្ម អោយបានទៀងទាត់ តាមប្រតិទិនដែលបានកំណត់ក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ ។ ក្នុងករណីចាំបាច់ ផែនការលទ្ធកម្មអាចកែតំរូវនៅឆមាសទី២នៃឆ្នាំសារពើពន្ធ។

-ប្រធានស្ថាប័នអនុវត្តលទ្ធកម្មមានភារកិច្ចគ្រប់គ្រង និង ត្រួតពិនិត្យជាប្រចាំរាល់កិច្ចលទ្ធកម្មរបស់ស្ថាប័នខ្លួន ហើយត្រូវធានាអោយបានថា រាល់កិច្ចលទ្ធកម្ម រួមទាំងការងារវិសហមជ្ឈការលទ្ធកម្ម សុទ្ធតែត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ តាមវិធីសាស្ត្រ តាមនីតិវិធី និងតាមផែនការលទ្ធកម្ម ។

-ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវផ្ញើរបាយការណ៍ប្រចាំខែ ស្តីពីការអនុវត្តន៍គ្រប់កិច្ចលទ្ធកម្ម រួមទាំងទិន្នន័យនៃកិច្ចសន្យាទាំងអស់ និងការងារវិសហមជ្ឈការ ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុតាមរយៈនាយកដ្ឋានលទ្ធកម្មសាធារណៈ អោយបានទៀងទាត់រៀងរាល់ខែ ។

## III.មូលដ្ឋានគ្រឹះសំរាប់រៀបចំផែនការលទ្ធកម្ម

ដើម្បីកសាងបាននូវផែនការលទ្ធកម្មមួយ ដែលមានលក្ខណៈច្បាស់លាស់ គ្រប់ជ្រុងជ្រោយ ហើយអាចជឿទុកចិត្តបាន មន្ត្រីលទ្ធកម្មត្រូវផ្តោតការយកចិត្តទុកដាក់ លើការងារសំខាន់ៗមួយចំនួនដូចខាងក្រោម :

-ត្រូវផ្អែកលើកញ្ចប់ថវិកាប្រចាំឆ្នាំសារពើពន្ធ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានព្រមព្រៀងជាគោលការណ៍ ដើម្បីធ្វើជាមូលដ្ឋានសំរាប់រៀបចំផែនការលទ្ធកម្ម ។

-ត្រូវប្រមូលផ្តុំនូវតំរូវការប្រើប្រាស់ប្រចាំឆ្នាំរបស់ស្ថាប័នខ្លួន ទាំងទំនិញ សំណង់ និង សេវា ដោយបែងចែកជាបីប្រភេទផ្សេងគ្នាគឺ :

·ប្រភេទ I : ទំនិញ

·ប្រភេទ II : សំណង់

·ប្រភេទ III : សេវា ( សេវាកម្ម និងសេវាទីប្រឹក្សា)

-ត្រូវសិក្សាអំពីតំរូវការ លក្ខណៈបច្ចេកទេស ភាពស្មុគស្មាញ ល័ក្ខខ័ណ្ឌការងារ កត្តាចាំបាច់ ។ល។ របស់មុខសញ្ញាលទ្ធកម្មនីមួយៗ ដែលជាផ្នែកសំខាន់ នៃឯកសារលទ្ធកម្ម ដើម្បីទាក់ទាញ ការប្រកួតប្រជែងអោយបានទូលំទូលាយ ។

-ត្រូវប្រមូលផ្តុំតំរូវការដែលស្ថិតក្នុងប្រភេទដូចគ្នា ហើយមានលក្ខណៈបច្ចេកទេសដូចគ្នា ឬស្រដៀងគ្នា ឬ បំរើអោយការងារតែមួយ ដូចជាប្រភេទ នៃគ្រឿងសង្ហារឹម ឬ សំភារៈការិយាល័យ សំរាប់ " ទំនិញ " ឬ ការងារសាងសង់តូចតាចមួយចំនួនដែលស្ថិតនៅជិតៗ គ្នាជាដើម សំរាប់ "សំណង់" ចាំបាច់ត្រូវបញ្ចូលក្នុងក្រុមតែមួយដែលហៅថា "ឡូត៍លទ្ធកម្ម" ដើម្បីធ្វើកិច្ចលទ្ធកម្មតែមួយលើក ។ ឡូត៍លទ្ធកម្មមួយចំនួន ដែលមានភាពប្រហាក់ប្រហែលគ្នា ឬ ស្រដៀងគ្នាត្រូវបញ្ចូលគ្នា ជាក្រុមធំមួយហៅថា " កញ្ចប់លទ្ធកម្ម" សំរាប់ធ្វើកិច្ចលទ្ធកម្ម តែមួយលើក ។ ការកំណត់ឡូត៍លទ្ធកម្ម និង កញ្ចប់លទ្ធកម្ម ជាទូទៅត្រូវបានប្រើប្រាស់សំរាប់តែទំនិញ និងសំណង់ប៉ុណ្ណោះ ។

ជាទូទៅ ឡូត៍លទ្ធកម្មទាំងអស់ត្រូវប្រមូលផ្តុំជាកញ្ចប់លទ្ធកម្ម ដើម្បីបង្កើនគំរិត និងគុណភាពនៃការប្រកួតប្រជែង ។

វិធានដូចខាងក្រោមត្រូវអនុវត្តនៅពេលប្រមូលផ្តុំទំនិញ ឬ សំណង់អោយទៅជាឡូត៍លទ្ធកម្ម ឬកញ្ចប់លទ្ធកម្មដែលអាចធ្វើកិច្ចលទ្ធកម្មតែមួយលើក :

·ទំនិញ ឬ សំណង់ច្រើនមុខដែលត្រូវធ្វើកិច្ចលទ្ធកម្មតាមវិធីសាស្ត្រតែមួយ ត្រូវធ្វើកិច្ចលទ្ធកម្ម តែមួយលើក ។

·ទំនិញ ឬ សំណង់ច្រើនមុខដែលស្ថិតក្នុងល័ក្ខខ័ណ្ឌកិច្ចសន្យាដូចគ្នា ត្រូវធ្វើកិច្ចលទ្ធកម្ម តែមួយលើក ។

·ទំនិញ ឬ សំណង់ច្រើនមុខដែលត្រូវរៀបចំសំរាប់កិច្ចលទ្ធកម្មក្នុងពេលតែមួយ ត្រូវធ្វើការដេញថ្លៃតែមួយលើក ។

·ទំនិញ ឬ សំណង់ច្រើនមុខដែលមានលក្ខណៈបច្ចេកទេសប្រហាក់ប្រហែលគ្នា ឬ ត្រូវប្រគល់ជូនអ្នកប្រើប្រាស់តែមួយ ត្រូវធ្វើកិច្ចលទ្ធកម្មតែមួយលើក ។

មិនអនុញ្ញាតអោយមានជាដាច់ខាត ចំពោះការបំបែកគំរោង ទៅជាគំរោងតូចៗ ដើម្បីបញ្ចៀសការដេញថ្លៃ ជាសាធារណៈ ។

-ត្រូវផ្អែកលើតំលៃទីផ្សារដើម្បីធ្វើការប៉ាន់ស្មាន តំលៃឯកត្តា តំលៃសរុប និង តំលៃសរុបរួមក្នុងមួយឡូត៍លទ្ធកម្ម

ឬ មួយមុខសញ្ញាលទ្ធកម្ម ឬ មួយកញ្ចប់លទ្ធកម្ម ឬ មួយគំរោងដែលត្រូវធ្វើកិច្ចលទ្ធកម្មមួយលើក១ ។ តំលៃសរុប នៃកិច្ចលទ្ធកម្មទាំងបីប្រភេទ នឹងបង្ហាញអំពីទឹកប្រាក់ដែលត្រៀមចំណាយសំរាប់ការទូទាត់ប្រចាំឆ្នាំ។

-ផ្អែកលើតំលៃសរុប និងភាពស្មុគស្មាញរបស់គំរោង ឬ មុខសញ្ញាលទ្ធកម្មនីមួយ១ ត្រូវកំណត់វិធីសាស្ត្រអោយបានសមស្រប ពោលគឺត្រូវបែងចែកអោយបានច្បាស់លាស់ថា គំរោងណាខ្លះត្រូវអនុវត្ត តាមវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែង ជាលក្ខណៈអន្តរជាតិ គំរោងណាខ្លះត្រូវអនុវត្ត តាមវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក ហើយប៉ុន្មានគំរោងត្រូវអនុវត្តតាមវិធីសាស្ត្រពិគ្រោះថ្លៃ ឬស្ទង់តំលៃ ទៅតាមក៏រិតកំណត់ទឹកប្រាក់ដូចមានក្នុងតារាងជូនភ្ជាប់ ។

-ត្រូវវិភាគ និង កំណត់រយៈពេលគ្រប់ដំណាក់កាលក្នុងដំណើរការលទ្ធកម្មដែលទាក់ទងនឹងគំរោងនីមួយ១ ។ វិធីសាស្ត្រលទ្ធកម្មខុសគ្នា តំរូវអោយប្រើរយៈពេលខុសគ្នា វែង ឬ ខ្លី អាស្រ័យលើក៏រិតទឹកប្រាក់ និង ភាពស្មុគស្មាញនៃមុខសញ្ញាលទ្ធកម្ម ។ ចំពោះកិច្ចលទ្ធកម្មដែលមានទឹកប្រាក់ធំ និង មានលក្ខណៈស្មុគស្មាញត្រូវគិតពេលវេលា បន្ថែមសំរាប់ការពិនិត្យ របស់គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតំលៃ និងប្រគល់កិច្ចសន្យា (គបវប) និងការពិនិត្យឡើងវិញរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-ការរៀបចំធ្វើផែនការលទ្ធកម្ម ត្រូវបានបែងចែកជា ដំណាក់កាល ដូចខាងក្រោម :

១-ដំណាក់កាលរៀបចំ :

- ការរៀបចំយថាប្រភេទ និងការប៉ាន់ស្មានតំលៃគំរោង
- ការរៀបចំឯកសារដេញថ្លៃ
- ការអនុម័តលើឯកសារដេញថ្លៃ (ក្រោមសិទ្ធិសំរេច)
- ការផ្តល់ទិដ្ឋាការយល់ព្រមលើឯកសារដេញថ្លៃ ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (ករណីលើសសិទ្ធិសំរេច) ។

២-បុរេលក្ខណៈសម្បត្តិ (ករណីចាំបាច់) :

- ការរៀបចំឯកសារបុរេលក្ខណៈសម្បត្តិ
- ការរៀបចំលិខិតជូនដំណឹង ដើម្បីផ្សព្វផ្សាយ
- ការផ្សព្វផ្សាយ លក់ ទទួល បើកឯកសារបុរេលក្ខណៈសម្បត្តិ
- ការវាយតំលៃជ្រើសរើសក្រុមហ៊ុន ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

៣-ដំណាក់កាលផ្សព្វផ្សាយ និងបើកឯកសារដេញថ្លៃ :

- ការរៀបចំលិខិតជូនដំណឹង ស្តីអំពីដំណើរការកិច្ចលទ្ធកម្ម
- ការផ្សព្វផ្សាយ (លក់ ទទួល បើកឯកសារដេញថ្លៃ)
- ការចែកកំណត់ហេតុបើកឯកសារដេញថ្លៃ

៤-ដំណាក់កាលវាយតំលៃ :

- ការរៀបចំវាយតំលៃលើសំណើដេញថ្លៃ



Mo

•ការពិនិត្យនិងផ្តល់អនុសាសន៍របស់ គបវប

•ការពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ( ករណីលើសសិទ្ធិសំរេច)

៥-ដំណាក់កាលចុះកិច្ចសន្យា :

•ការធ្វើលិខិតជូនដំណឹងស្តីពីការសំរេចប្រគល់កិច្ចសន្យា

•ការរៀបចំកិច្ចសន្យា

•ការចុះហត្ថលេខាលើកិច្ចសន្យា

៦-ដំណាក់កាលប្រគល់-ទទួល :

•រយៈពេលប្រគល់-ទទួល ( ពេលចាប់ផ្តើម-ពេលបញ្ចប់)

•ចំនួនលើកដែលត្រូវប្រគល់-ទទួល

•រយៈពេលធានាគុណភាព

៧-ដំណាក់កាលទូទាត់ :

•រយៈពេលទូទាត់ ( ពេលចាប់ផ្តើម-ពេលបញ្ចប់)

•ចំនួនលើកដែលត្រូវទូទាត់

-ដំណាក់កាលនីមួយៗ ខាងលើត្រូវគិតចំនួនថ្ងៃសមស្រប សំរាប់បំពេញក្នុងតារាងផែនការលទ្ធកម្ម ដូចមានគំរូភ្ជាប់ជាមួយ ។

-រយៈពេលធ្វើកិច្ចលទ្ធកម្មគិតពីថ្ងៃចាប់ផ្តើមរៀបចំឯកសារ រហូតដល់ថ្ងៃចុះហត្ថលេខាលើកិច្ចសន្យាចប់សព្វគ្រប់ត្រូវបានគិតជាមធ្យមដូចខាងក្រោម :

<u>**តារាងកំណត់រយៈពេលមធ្យមសំរាប់ធ្វើកិច្ចលទ្ធកម្ម**</u>

| ល.រ | មុខសញ្ញាលទ្ធកម្ម | កាលបរិច្ឆេទចាប់ផ្តើម | កាលបរិច្ឆេទចុះកិច្ចសន្យា | រយៈពេល | | | | | | ការប្រគល់-ទទួល | | ការទូទាត់ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលសរុប | រៀបចំឯកសារ | បុរេលក្ខណៈសម្បត្តិ | ការផ្សព្វផ្សាយ ដាក់ទទួលពាក្យ និងបើកឯកសារដេញថ្លៃ | ការវាយតំលៃ | ការចុះកិច្ចសន្យា | កាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់(ខែ) | ចំនួនលើក | កាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់(ខែ) | ភាគរយក្នុងលើកនីមួយៗ |
| | | | | ចំនួនថ្ងៃ | ចំនួនថ្ងៃ | ចំនួនថ្ងៃ | ចំនួនថ្ងៃ | ចំនួនថ្ងៃ | ចំនួនថ្ងៃ | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ |
| 1 | ដបអ | | | 120 | 20 | - | 50 | 30 | 20 | | | | |
| 2 | ដបស | | | 50 | 10 | - | 20 | 10 | 10 | | | | |
| 3 | ពថ | | | 40 | 8 | - | 15 | 10 | 7 | | | | |
| 4 | សត | | | 17 | 5 | - | - | 7 | 5 | | | | |

<u>កំណត់សំគាល់</u> : ដបអ :ដេញថ្លៃដោយប្រកួតប្រជែងជាអន្តរជាតិ ដបស : ដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក ពថ : ពិគ្រោះថ្លៃ សត : ស្នងតំលៃ

-ចំពោះកិច្ចលទ្ធកម្ម ដែលត្រូវធ្វើបុរេលក្ខណៈសម្បត្តិ រយៈពេលសរុបត្រូវបូកបន្ថែមរយៈពេលធ្វើបុរេលក្ខណៈសម្បត្តិ ។ រយៈពេលសំរាប់ធ្វើបុរេលក្ខណៈសម្បត្តិត្រូវបានគិតជាមធ្យម ៤០ថ្ងៃ ។

-រយៈពេលប្រគល់-ទទួល និងទូទាត់អាស្រ័យលើស្ថាប័នអនុវត្តលទ្ធកម្ម ពិនិត្យជាក់ស្តែង ដោយផ្អែកលើ

តារាងកំណត់ទឹកប្រាក់

ដើម្បីអនុវត្តវិធីសាស្ត្រលទ្ធកម្ម : ទំនិញ សំណង់ និង សេវា

| វិធីសាស្ត្រ | កំរិតទឹកប្រាក់តាមប្រភេទលទ្ធកម្ម | | |
|---|---|---|---|
| | ទំនិញ | សំណង់ | សេវា |
| ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ (ដបអ) | ចាប់ពី ១.០០០ លានរៀលឡើង | ចាប់ពី ១.២០០ លានរៀលឡើង | ចាប់ពី ៨០០ លានរៀលឡើង |
| ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក (ដបស) | ចាប់ពី ១០០ លានរៀល ដល់ក្រោម ១.០០០ លានរៀល | ចាប់ពី ១០០ លានរៀលដល់ក្រោម ១.២០០ លានរៀល | ចាប់ពី១០០ លានរៀលដល់ក្រោម ៨០០ លានរៀល |
| ការពិគ្រោះថ្លៃ (ពថ) | ចាប់ពី ២០ លានរៀល ដល់ក្រោម ១០០ លានរៀល | ចាប់ពី ២០ លានរៀលដល់ក្រោម ១០០ លានរៀល | ក្រោម ១០០ លានរៀល |
| ការស្ទង់តំលៃ (សត) | ក្រោម ២០ លានរៀល | ក្រោម ២០ លានរៀល | |
| លទ្ធកម្មដោយឡែក | -មិនកំណត់ទឹកប្រាក់<br>-ត្រូវមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | -មិនកំណត់ទឹកប្រាក់<br>-ត្រូវមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | |

* ការកំណត់ទឹកប្រាក់នេះ អាចប្រែប្រួលតាមការសំរេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួង ស្ថាប័ន ខេត្ត-ក្រុង និងសហគ្រាសសាធារណៈ...

## តារាងផែនការលទ្ធកម្ម

**ឆ្នាំ.........**

ឯកត្តា : ពាន់រៀល

| ល.រ | ប្រភេទ និងមុខសញ្ញាលទ្ធកម្ម | តំលៃគំរោង | តំលៃគំរោងតាមវិធីសាស្ត្រនីមួយៗ * | | | កាលបរិច្ឆេទចាប់ផ្តើម (ខែ) | កាលបរិច្ឆេទចុះកិច្ចសន្យា (ខែ) | ការប្រគល់-ទទួល | | | ការទូទាត់ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ដបស | ពថ | សត | | | ចាប់ផ្តើម (ខែ) | បញ្ចប់ (ខែ) | ចំនួនលើក | ចាប់ផ្តើម (ខែ) | បញ្ចប់ (ខែ) | ភាគរយក្នុងមួយលើកៗ |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ |
| I-លទ្ធកម្មទំនិញ | | | | | | | | | | | | | |
| 1 | | | | | | | | | | | | | |
| 2 | | | | | | | | | | | | | |
| 3 | | | | | | | | | | | | | |
| សរុប I | តំលៃគំរោង | | | | | | | | | | | | |
| | ចំនួនគំរោង | | | | | | | | | | | | |
| II-លទ្ធកម្មសំណង់ | | | | | | | | | | | | | |
| 1 | | | | | | | | | | | | | |
| 2 | | | | | | | | | | | | | |
| 3 | | | | | | | | | | | | | |
| សរុប II | តំលៃគំរោង | | | | | | | | | | | | |
| | ចំនួនគំរោង | | | | | | | | | | | | |
| III-លទ្ធកម្មសេវា | | | | | | | | | | | | | |
| 1 | | | | | | | | | | | | | |
| 2 | | | | | | | | | | | | | |
| 3 | | | | | | | | | | | | | |
| សរុប III | តំលៃគំរោង | | | | | | | | | | | | |
| | ចំនួនគំរោង | | | | | | | | | | | | |
| សរុបរួម | តំលៃគំរោង : I+II+III | | | | | | | | | | | | |
| | ចំនួនគំរោង : I+II+III | | | | | | | | | | | | |

........ថ្ងៃ ខែ ឆ្នាំ២០០..
បានឃើញ និងឯកភាព
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

........ថ្ងៃ ខែ ឆ្នាំ២០០..
បានឃើញ និងឯកភាព
ប្រធានស្ថាប័នអនុវត្តលទ្ធកម្ម
និងជាប្រធាន គបវប

...........ថ្ងៃ ខែ ឆ្នាំ២០០..
ប្រធានអង្គភាពលទ្ធកម្ម(អល)

* កំណត់សំគាល់ : ក្នុងករណីមានអនុវត្តតាមវិធីសាស្ត្រ ដបអ ត្រូវបង្កើតកូឡោនបន្ថែមមួយទៀតនៅ... ដបស ។